## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត


បោះពុម្ព និងផ្សព្វផ្សាយដោយ
គ.ជ.ប

ឆ្នាំ ២០១៨



ទូរស័ព្ទ/ទូរសារៈ ០២៣ ២១៤ ៣៧៤. ២១៤ ២៣១. ០១២ ៨៥៥ ០១៨
E_mail: necinfo@forum.org.kh, www.necelect.org.kh, www.voterlist.org.kh


**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
## (គ.ជ.ប)

# សៀវភៅណែនាំ

# ស្តីពី

# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦

# មាតិកា

ទំព័រ


**គោលចំណង** ---------- i

**អក្សរកាត់** ---------- ii

**ជំពូកទី ១ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** ---------- ១

១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ---------- ១

២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ---------- ១

៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ---------- ២

៤. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ---------- ២

៥. ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ---------- ៣

៦. ការពិនិត្យ និងសម្រេចរបស់ គ.ជ.ប ---------- ៤

**ជំពូកទី ២ នីតិវិធីនៃការដាក់ ការទទួល និងដោះស្រាយពាក្យបណ្តឹង** ---------- ៥

**ផ្នែកទី ១ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់** ---------- ៥

១. ពាក្យបណ្តឹង ---------- ៥

២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ---------- ៦

**ផ្នែកទី២ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** ---------- ៧

១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---------- ៧

១.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---------- ៧

១.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---------- ៧

**ផ្នែកទី ៣ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ** ---------- ៩

I. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ---------- ៩

១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប ---------- ៩

១.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.សប ---------- ៩

១.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប ---------- ១២

២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប----- ១៤

២.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គធ.ខប ---------------- ១៤

២.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប------------------------ ១៦

៣. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប----- ១៩

៣.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ----------------- ១៩

៣.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប --------------------------- ២១

៤. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ ក្រុមប្រឹក្សាធម្មនុញ្ញ--------------------------------------------------------------- ២៣

៤.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ -២៣

៤.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---------- ២៤

II. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត ------------------------------------២៦

**ផ្នែកទី ៤ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត**---២៨

១. ការតវ៉ា ឬ/និងការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ ----------------២៨

១.១ ការតវ៉ា ឬ/និងការជំទាស់នៅ គ.ក.ប/គ.ក.រ-------------------------------------- ២៨

១.២ ការដោះស្រាយការតវ៉ា ឬ/និងការជំទាស់នៅ គ.ក.ប/គ.ក.រ --------------- ២៨

២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.សប---២៩

២.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គឃ.សប -------------- ២៩

២.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.សប -----------------------៣២

៣. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប -- ៣៤

៣.១ នីតិវិធីនៃការដាក់ពាក្យបណ្ដឹងនៅ គធ.ខប-------------------------------------៣៤

៣.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប------------------------ ៣៦

៤. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយនៅ គ.ជ.ប-------------------- ៤១

៤.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប------------------ ៤១

៤.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប----------------------------៤៣

**ផ្នែកទី ៥ បណ្ដឹងទាក់ទងនឹងការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត** ----------------------------------------------------------------------- ៤៧

១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប---- ៤៧

១.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ------------------៤៧

១.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ------------------------ ៤៩

២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ ក្រុមប្រឹក្សាធម្មនុញ្ញ ------------------------ ៥១

២.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ---- ៥១

២.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ------------ ៥១

**ផ្នែកទី ៦ នីតិវិធីអនុវត្តសេចក្តីសម្រេចស្តាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់** ------------------------ ៥៣

**ជំពូកទី ៣ សមត្ថកិច្ច នីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង** ------------------------ ៥៤

**ផ្នែកទី ១ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ** ------------------------ ៥៤

១. សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ------------------------ ៥៤

១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប------------ ៥៤

១.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ------------------------ ៥៥

១.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ------------------------ ៥៦

២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ------------------------ ៥៦

២.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ----- ៥៦

២.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប------------------------ ៥៧

២.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប------------------------ ៥៧

**ផ្នែកទី២ សិទ្ធិ និងកាតព្វកិច្ចដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី**------------------------ ៥៩

១.សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ------------------------ ៥៩

២.សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង ------------------------ ៦០

៣.សិទ្ធិ និងកាតព្វកិច្ចរបស់ចុងចម្លើយ------------------------ ៦១

៤.សិទ្ធិ និងកាតព្វកិច្ចរបស់មេធាវី ឬតំណាង------------------------ ៦១

៥.សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ------------------------ ៦១

**ផ្នែកទី ៣ នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ** -------------------- ៦៣
១. ប្រភេទសវនាការ -------------------------------------------------------------------- ៦៣
២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ---------------- ៦៤
៣. ពេលវេលាដោះស្រាយពាក្យបណ្តឹង ------------------------------------------------ ៦៤
៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬ សវនាការ -------- ៦៤
៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គឃ.សប---- ៦៤
៤.២ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬ
បើកសវនាការនៅ គធ.ខប------------------------------------------------- ៦៤
៤.៣ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប ---------------------------------- ៦៥
៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬ
លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ -------------------------- ៦៥
៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ
ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ------------------------------------ ៦៦
៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ -------------- ៦៨
៨. មធ្យោបាយបង្ហាញភស្តុតាង -------------------------------------------------------- ៦៩
៩. ការបំពេញ និងការប្រើប្រាស់ ទ.១២០៣------------------------------------------ ៧០
១០.ទម្រង់ផ្សេងៗសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ------- ៧២

**ឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី ១ ទម្រង់បែបបទពាក្យបណ្តឹង** (ទ.១២០២)-------------------- ៧៣
**ឧបសម្ព័ន្ធទី ២ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច** (ទ.១២០៣)------- ៧៤
**ឧបសម្ព័ន្ធទី ៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំ
សម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង** ------------ ៧៥
**ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារនៃសម្បថ** -------------------------------- ៧៦

# គោលបំណង

សៀវភៅណែនាំស្តីពី**នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

សៀវភៅណែនាំនេះ រៀបចំឡើងដើម្បីជាជំនួយស្មារតីសម្រាប់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ឱ្យបានយល់ដឹងអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ សៀវភៅណែនាំនេះ ចែកចេញជា ៣ (បី) ជំពូក ៖

**ជំពូកទី ១** បង្ហាញអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

**ជំពូកទី ២** បង្ហាញដោយសង្ខេបអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង នៅក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដំណាក់កាលឃោសនាបោះឆ្នោត និងដំណាក់កាលបោះឆ្នោតរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

**ជំពូកទី ៣** បង្ហាញដោយសង្ខេបអំពីនីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ក្នុងនោះមានជាអាទិ៍ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំសម្រេច ក្រុមប្រឹក្សាជំនុំជម្រះ ប្រភេទសវនាការ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង។

ផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះមាន ៤ (បួន) ឧបសម្ព័ន្ធ៖

- ឧបសម្ព័ន្ធទី១ ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)
- ឧបសម្ព័ន្ធទី២ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)
- ឧបសម្ព័ន្ធទី៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង
- ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារនៃសម្បថ។

# អក្សរកាត់

| | |
|---|---|
| -ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| -ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| -បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ប.ន.ត.រ |
| -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| -គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| -លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| -គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| -គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| -ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| -ទម្រង់បែបបទលេខ | ទ. |
| -ទម្រង់បែបបទកំណត់ហេតុនៃការបោះឆ្នោត | ទ.១១០១ |
| -ទម្រង់បែបបទកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត | ទ.១១០២ |
| -ទម្រង់បែបបទតារាងកត់ត្រាសំឡេងឆ្នោត | ទ.១១០៨ |
| -ទម្រង់បែបបទពាក្យបណ្តឹង | ទ.១២០២ |
| -ទម្រង់បែបបទសម្រង់សេចក្តីសម្រេច | ទ.១២០៣ |

# ជំពូកទី ១
# ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ

## ១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

អនុលោមតាមមាត្រា ២៣ នៃ ច.ប.ត.រ ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១.១ មានសញ្ជាតិខ្មែរពីកំណើត។

១.២ មានអាយុ ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត។

១.៣ មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

១.៤ មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

១.៥ មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

## ២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ៖

២.១ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

២.២ ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

២.៣ ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

២.៤ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

២.៥ ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប ឬ

២.៦ សមាជិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

២.៧ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

២.៨ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

## ៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពល ខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទ រហូតដល់ថ្ងៃប្រកាស លទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការ ឃោសនាបោះឆ្នោត។

លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាព អាចភ្ជាប់ មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។ ក្នុងករណីធ្វើមិនទាន់ ត្រូវធ្វើពាក្យសុំច្បាប់ឈប់ពិសេសជូន គ.ជ.ប ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកយុទ្ធនាការឃោសនាបោះឆ្នោត។

## ៤. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

**ក.** ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវ ចាប់ផ្តើម ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវ តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពី គណបក្សនយោបាយ ហើយមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រជាផ្លូវការ ត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោត (ទ.១០០៨) ទៅនាយកដ្ឋានសេវាកម្មច្បាប់ និង វិវាទកម្ម នៃ គ.ជ.ប ។

**ខ.** ទ.១០០៨ ត្រូវបានផ្តល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយ ដែល មានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គណបក្ស នយោបាយត្រូវបំពេញ ទ.១០០៨ នេះ ជា ២ (ពីរ) ច្បាប់។

**គ.** ទ.១០០៨ ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬ តំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ពីប្រធាន គណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិបន្ត ត្រូវតែមានការយល់ព្រម ជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។

**ឃ.** ទ.១០០៨ ត្រូវភ្ជាប់មកជាមួយនូវ ៖

១- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅ ក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់

២- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ
៣- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ
៤- បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ
៥- ឈ្មោះមណ្ឌលដែលគណបក្សនយោបាយ មានបំណងទៅឈរ និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌល ត្រូវមានបេក្ខជនគ្រប់តាមចំនួនអាសនៈ និងតាមគំរូដែល គ.ជ.ប ផ្តល់ជូន។ ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈ ១ (មួយ) ឬ ២ (ពីរ) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិច ៣ (បី) រូប
៦- សេចក្តីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយនៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា
៧- លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ
៨- សេចក្តីប្រកាសរបស់គណបក្សនយោបាយថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោត ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ត.រ ប.ន.ត.រ របស់ គ.ជ.ប និងក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ
៩- បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ
១០- បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដែលចេញដោយរតនាគារជាតិ។

## ៥. ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

**ក.** ការទទួលពាក្យសុំចុះបញ្ជី ទ.១០០៨ មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ២:០០ នាទី ដល់ម៉ោង ៥:៣០ នាទី។

ខ. គ.ជ.ប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ ទុកជាឯកសារ។

គ. បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារ ដែលបានទទួល ដោយត្រូវចុះកាលបរិច្ឆេទប្រគល់ ទទួល និងចុះហត្ថលេខា ឬស្នាមមេដៃរបស់អ្នកប្រគល់ ទទួល។

## ៦. ការពិនិត្យ និងសម្រេចរបស់ គ.ជ.ប

ក. គ.ជ.ប ត្រូវពិនិត្យសម្រេចលើ ទ.១០០៨ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

ខ. ក្នុងករណី គ.ជ.ប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

គ. ក្នុងករណី គ.ជ.ប ពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ ដូចមានចែងក្នុង**ចំណុច ៤ (ទំព័រ២)** គ.ជ.ប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ឬកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានទទួលលិខិតជូនដំណឹង។

ឃ. ក្នុងករណីសាមីគណបក្សនយោបាយ ពុំបានបំពេញលក្ខខណ្ឌតាមការកំណត់ ដូចមានចែងក្នុង**ចំណុច គ (ទំព័រ៤)** គ.ជ.ប ត្រូវសម្រេចបដិសេធការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ដោយបំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេចចំនួន ៣ (បី) ច្បាប់ រួចផ្ញើជូនគណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

# ជំពូកទី ២
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង

## ផ្នែកទី ១
## ការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់តាមឋានានុក្រម ទៅ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ អំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវដូចចែងក្នុង ច.ប.ត.រ ឬ/និង ប.ន.ត.រ ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែ ៖

- ការប្ដឹងទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះដែលត្រូវប្ដឹងដោយសាមីខ្លួន ឬសាមីគណបក្សនយោបាយ
- ការប្ដឹងទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត/រាប់សន្លឹកឆ្នោត ដែលត្រូវប្ដឹងដោយភ្នាក់ងារគណបក្សនយោបាយ
- ការប្ដឹងទាក់ទងនឹងការប្រកាសលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោត ដែលត្រូវប្ដឹងដោយ គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ឬតំណាង

### ១. ពាក្យបណ្ដឹង

ពាក្យបណ្ដឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ៣ (បី) ច្បាប់ **(ចំពោះបណ្ដឹងតវ៉ា)** ឬចំនួន ៤ (បួន) ច្បាប់ **(ចំពោះបណ្ដឹងជំទាស់)**។ គឃ.សប ឬមន្ត្រីបោះឆ្នោត ត្រូវប្រគល់ ទ.១២០២ ដល់អ្នកប្ដឹងដើម្បីប្ដឹង ឬប្ដឹងបន្ត ប្រសិនបើមានការស្នើសុំ។

អ្នកប្ដឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជួសខ្លួនបាន។

ពាក្យបណ្ដឹង ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

**១-** ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

**២-** កម្មវត្ថុនៃបណ្ដឹង

**៣-** ប្រភេទនៃអំពើល្មើស

៤- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង

៥- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលបានរំលោភ

៦- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់

៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន

៨- ភស្តុតាងផ្សេងៗទៀត បើមាន។

ពាក្យបណ្តឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

ពាក្យបណ្តឹងប្តឹងពីអញ្ញាតជន[១] ត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប ត្រូវជូនដំណឹងទៅអ្នកប្តឹងវិញអំពីករណីនេះ ក្នុងរយៈពេលសមស្រប។

## ២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់

ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យផ្លូវការ។

**ឧទាហរណ៍៖**

ប្រសិនបើរឿងហេតុកើតឡើងក្នុងដំណាក់កាលឃោសនាបោះឆ្នោត នៅថ្ងៃទី២៥ រយៈពេលនៃការប្តឹងតវ៉ាគឺ ៣ ថ្ងៃក្រោយថ្ងៃកើតហេតុ ហើយចាប់ផ្តើមដំណើរការពីថ្ងៃបន្ទាប់ គឺថ្ងៃទី២៦ រយៈពេលនោះនឹងត្រូវផុតនៅថ្ងៃទី២៨ វេលាម៉ោង ១៧:៣០ នាទី ប៉ុន្តែប្រសិនបើថ្ងៃទី២៨ ត្រូវជាថ្ងៃឈប់សម្រាកដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករប្រចាំឆ្នាំ រយៈពេលនេះនឹងត្រូវចប់នៅថ្ងៃទី២៩ វេលាម៉ោង ១៧:៣០ នាទីវិញ។

---

[១] ជនមិនស្គាល់អត្តសញ្ញាណ

# ផ្នែកទី២
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

## ១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ១.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គ.ជ.ប សាមីគណបក្សនយោបាយ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ។

**ខ.** ក្នុងករណីទទួលសេចក្តីសម្រេចបដិសេធ ប៉ុន្តែសាមីគណបក្ស ឬតំណាងពុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅតាមពេលវេលា ដូចមានចែងក្នុង **ចំណុច ក (ទំព័រ៧)** នោះទេ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា។

**គ.** នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ១.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើពាក្យបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

**ខ.** នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**គ.** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា។

## ២. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ



## ផ្នែកទី៣
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ

ផ្នែកទី៣ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬប្រព្រឹត្តដោយគណបក្សនយោបាយ ឬប្រព្រឹត្តដោយជនដែលជាមន្ត្រីបោះឆ្នោតដែលអាចនាំឱ្យមានការផាកពិន័យ និងដែលអាចកើតឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រួមទាំងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោតផង។

### I. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្ដឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយទៅ គឃ.សប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ឬទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬផ្សះផ្សានៅ គឃ.សប ឬបន្តប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ឬបន្តប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គ.ជ.ប ។ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ មួយចំនួនដូចមានចែងក្នុង**ចំណុច ១ (ទំព័រ ៥)** ។

### ១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.សប

#### ១.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គឃ.សប

**ក.** អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់ ។ ក្នុងករណីដែលអ្នកប្ដឹងមកប្ដឹងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពី ទ.១២០២ គឃ.សប ត្រូវណែនាំអ្នកប្ដឹងឱ្យបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។ អ្នកប្ដឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ថតចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹង

ដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹង ឬតវ៉ាជូសខ្លួនបាន។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

គ. បន្ទាប់មកសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គឃ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា **"ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដែលជាហេតុផ្ដាច់សិទ្ធិ[២] ក្នុងការប្ដឹងមក គឃ.សប ។ ដូចនេះ គឃ.សប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"** ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

---

[២] ការបាត់បង់សិទ្ធិ ដោយហេតុមិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវឱ្យបំពេញក្នុងរយៈពេលកំណត់

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចចែងក្នុង**ចំណុច ១ (ទំព័រ៥)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទ៍ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គឃ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា **"ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ.."** ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.៣ ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់)** សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា បោះត្រា គឃ.សប លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ១.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គឃ.សប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គឃ.សប ពិនិត្យ និងយល់ឃើញថា៖

**ក.១** ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃបណ្តឹង មានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើ ច.ប.ត.រ គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់ថា **"ពាក្យបណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថាករណីនេះ ឬទាំងនេះពុំមែនជាសមត្ថកិច្ចរបស់ គឃ.សប"** ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គឃ.សប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម៖

- ប្រធាន គឃ.សប ឬតំណាង ជាប្រធានក្រុម
- សមាជិក គឃ.សប ១ (មួយ) នាក់ ជាសមាជិក
- សមាជិក គឃ.សប ១ (មួយ) នាក់ ជាលេខាធិការ។

**ខ.** ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជន

ដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង។

**គ.** បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះ មិនបានបំពានលើ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គឃ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប **គឃ.សប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់ កំណត់ដោយ គឃ.សប ។**

**ង.** គឃ.សប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ។

**ច.** ក្នុងការផ្សះផ្សា ប្រសិនបើភាគីទំនាស់៖

**ច.១** ព្រមព្រៀងគ្នា គឃ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ ផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះ ជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធ។

**ច.២** មិនព្រមព្រៀងគ្នាទេ គឃ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជា

បន្ទាន់មក គធ.ខប ពាក់ព័ន្ធ ទោះបីភាគីណាមួយមិនព្រមផ្តិតមេដៃក៏ដោយ។ គឃ.សប ត្រូវប្រាប់ភាគីថា ភាគីណាមួយមិនសុខចិត្តលទ្ធផលនៃការផ្សះផ្សា អាចដាក់ពាក្យបណ្តឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សារួច។

**ឆ.** គឃ.សប ត្រូវបើកការប្រជុំផ្សះផ្សាចំពោះរាល់ពាក្យបណ្តឹងគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ ប៉ុន្តែមិនមានអំណាចបើកអង្គប្រជុំសម្រេច និងចេញ ទ.១២០៣ ឡើយ។

**ជ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ.សប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុង**ជំពូកទី៣ ផ្នែកទី១ ចំណុច ១.១ នៃសៀវភៅណែនាំនេះ (ទំព័រ៥៤)**។

## ២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ២.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬការផ្សះផ្សានៅថ្នាក់ គឃ.សប ហើយដែលមានបំណងប្តឹងទៅ គធ.ខប អាចប្តឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា។ អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។

**ខ.** នៅពេលបានទទួលពាក្យបណ្តឹង សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង

២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា។

**គ.** បន្ទាប់មកសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិន

ព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

**ឃ.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថាៈ

**ឃ.១** ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុធ្លស់សិទ្ធិក្នុងការប្ដឹងមក គធ.ខប ។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**" ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.២** ពាក្យបណ្ដឹងមិនមានព័ត៌មានចាំបាច់ដូចក្នុង**ចំណុច ១ (ទំព័រ៥)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទ៍ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយ-លក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា "**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតគល់សិទ្ធិមិនត្រឹមត្រូវ..**" ហើយចុះហត្ថលេខា សរសេរ

ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.៣** ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់)** សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ.ខប រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គធ.ខប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី គធ.ខប ពិនិត្យ និងយល់ឃើញថា ៖

**ក.១** ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាម

លិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់ថា **"ពាក្យបណ្តឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថា ករណីនេះ ឬទាំងនេះពុំមែនជាសមត្ថកិច្ច របស់ គធ.ខប"** ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នា នៅថ្នាក់ គឃ.សប គធ.ខប ត្រូវពិនិត្យសម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់ថា **"ពាក្យបណ្តឹងនេះភាគីទំនាស់បានសះជានឹងគ្នារួចហើយ ហើយគ្មានហេតុផលថ្មីផ្សេងទៀត ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"** ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៤** ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោមៈ

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុម
- សមាជិក គធ.ខប ១ (មួយ) នាក់ ជាសមាជិក
- មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម ១(មួយ)នាក់ ជាលេខាធិការ។

**ខ.** ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខ

បោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្ដឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្ដឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្ដឹង ឬតំណាង។

**គ.** បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះ មិនបានបំពានលើ ច.ប.ត.រ ឬ ប.ន.ត.រ ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់បានបំពានលើ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប **គធ.ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់ កំណត់ដោយ គធ.ខប** ។

**ង.** គធ.ខប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ។

**ច.** ក្នុងការផ្សះផ្សា ប្រសិនបើភាគីទំនាស់៖

**ច.១** ព្រមព្រៀងគ្នា គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានេះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប ។

ច.២ មិនព្រមព្រៀងគ្នាទេ គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។ គធ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលាកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង។

**ឆ.** គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសវនាការ សេចក្តីសម្រេច និង ទ.១២០៣ ចំនួន ៥ (ប្រាំ) ច្បាប់ ដោយមានការចុះហត្ថលេខារបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ជ.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុង**ជំពូកទី៣ ផ្នែកទី១ ចំណុច ១.២ នៃសៀវភៅណែនាំនេះ (ទំព័រ៥៥)**។

## ៣. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ៣.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។ អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់ ។

**ខ.** នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

**គ.** បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

**ឃ.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

**ឃ.១** ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុថ្លស់សិទ្ធិក្នុងការប្ដឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**" ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.២** ពាក្យបណ្ដឹងមិនមានព័ត៌មានចាំបាច់ ដូចក្នុងចំណុច ១ **(ទំព័រ ៥)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិ ជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុង

កំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា "**ពាក្យបណ្តឹងមិនមានព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...**" ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

**ឃ.៣** ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

## ៣.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថាៈ

**ក.១** ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធ ទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ទៅអ្នកប្តឹងដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់ថា **"ពាក្យបណ្ដឹងនេះមិនអាចដោះស្រាយបានទេ ដោយហេតុថាករណីនេះ ឬទាំងនេះ ពុំមែនជាសមត្ថកិច្ចរបស់ គ.ជ.ប"** ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្ដឹង ដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយនៅ គធ.ខប គ.ជ.ប ត្រូវពិនិត្យសម្រេចថា ត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ទៅអ្នកប្ដឹង ដោយបញ្ជាក់ថា **"ពាក្យបណ្ដឹងនេះភាគីទំនាស់បានសះជានឹងគ្នារួចហើយ ហើយគ្មានហេតុផលថ្មីផ្សេងទៀត ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"** ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៤** ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ ដូចក្នុង**ចំណុច ១ (ទំព័រ៥)** គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

**ខ.** គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

**គ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកពាក្យបណ្ដឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្ដឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្ដឹង ដែលអាចយកមកដោះស្រាយ

បាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅដើមបណ្តឹងដើម្បីជូនជ្រាបថា ពាក្យបណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹង គ.ជ.ប **ត្រូវដោះស្រាយបណ្តឹងតាមពេលវេលាសមស្របជាបន្ទាន់**។

**ង.** គ.ជ.ប ត្រូវសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុ សេចក្តីសម្រេច និង ទ.១២០៣ ចំនួន ៥ (ប្រាំ) ច្បាប់ ដោយមានការចុះហត្ថលេខា របស់ប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចគណៈលេខាធិការសវនាការ ត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ច.** សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុង**ជំពូកទី៣ ផ្នែកទី១ ចំណុច ១.៣ នៃសៀវភៅណែនាំនេះ (ទំព័រ៥៦)**។

## ៤. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង នៅក្រុមប្រឹក្សាធម្មនុញ្ញ

### ៤.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹង នៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល

៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គ.ជ.ប ។

**ខ.** នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

## ៤.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការជាសាធារណៈដើម្បីពិនិត្យ និងសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

**ខ.** នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**គ.** សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា។

## ៥. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ចំពោះគ្រប់អំពើបំពានលើ ច.ប.ត.រ ឬ ប.ន.ត.រ



## II. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គ្រប់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្ដឹង គ.ក.ប/គ.ក.រ ឬ គឃ.សប ឬ គធ.ឧប ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្ដឹងទៅ គឃ.សប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ៩ ដល់ទំព័រ២៤)** ។

**ខ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គឃ.សប ដំបូងត្រូវប្ដឹងទៅ គធ.ឧប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ១៤ ដល់ទំព័រ២៤)** ។

**គ.** ពាក្យបណ្ដឹងពាក់ព័ន្ធសមាសភាព គធ.ឧប ឬមន្ត្រី លគធ.ឧប ឬមន្ត្រី គ.ជ.ប ដំបូងត្រូវប្ដឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ **(ទំព័រ១៩ ដល់ទំព័រ២៤)** ។

**ឃ.** ពាក្យបណ្ដឹងពាក់ព័ន្ធនឹងសមាសភាព គ.ជ.ប ត្រូវប្ដឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.គ.ជ.ប ។

ពាក្យបណ្ដឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្ដឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយពាក្យបណ្ដឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលរួចហើយ ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក្នុងករណីដែល៖**

- រកឃើញថា សមាជិក ឬមន្ត្រីនោះពិតជាបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មស្របតាម ច.ប.ត.រ ឬ ប.ន.ត.រ ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។
- រកឃើញថា សមាជិក ឬមន្ត្រីនោះបានគោរពតាម ច.ន.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្ដឹងនោះ ហើយពាក្យបណ្ដឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

## គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ចំពោះគ្រប់អំពើបំពានលើ ច.ប.ត.រ ឬ ប.ន.ត.រ

គំនូសបំព្រួញទី៣

**II. ការប្ដឹងពីជនដែលជាមន្ត្រីបោះឆ្នោត**



## ផ្នែកទី៤
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងភាពមិនប្រក្រតី នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត

ផ្នែកទី៤ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយដែលកើតមានឡើង ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត និងពាក្យបណ្ដឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលកើតមានឡើងក្នុងតំបន់ណាមួយ នៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។

### ១. ការតវ៉ា ឬ/និងការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ

#### ១.១ ការតវ៉ា ឬ/និងការជំទាស់នៅ គ.ក.ប/គ.ក.រ

**ក.** ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិតវ៉ា ឬជំទាស់នឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬភាពមិនប្រក្រតីនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងសេចក្ដីសម្រេចណាមួយរបស់ គ.ក.ប/គ.ក.រ នៅការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតដែលខ្លួនបំពេញការងារសង្កេតការណ៍ ដោយផ្ទាល់ភ្លាមៗទៅប្រធាន គ.ក.ប/គ.ក.រ ។

**ខ.** ភ្នាក់ងារគណបក្សនយោបាយ ត្រូវបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាងដែលនាំឱ្យប្រធាន គ.ក.ប/គ.ក.រ ជឿថាមានភាពមិនប្រក្រតី ឬមានការបំពាន ច.ប.ត.រ ឬ/និង ប.ន.ត.រ ។

#### ១.២ ការដោះស្រាយការតវ៉ា ឬ/និងការជំទាស់នៅ គ.ក.ប/គ.ក.រ

**ក.** ប្រធាន គ.ក.ប/គ.ក.រ ត្រូវធ្វើការដោះស្រាយភ្លាមនូវការតវ៉ា ឬជំទាស់ទាំងនោះ។

**ខ.** ប្រសិនបើយល់ឃើញថា ការតវ៉ា ឬជំទាស់ទាំងនោះ មានលក្ខណៈសមហេតុផល ប្រធាន គ.ក.ប/គ.ក.រ ត្រូវបញ្ឈប់ជាបណ្ដោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដើម្បីស្ដាប់ការតវ៉ា ឬជំទាស់របស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប/គ.ក.រ ដទៃទៀត។

**គ.** បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណីដែលបានលើកការតវ៉ា ឬជំទាស់ហើយ ប្រសិនបើប្រធាន គ.ក.ប/គ.ក.រ យល់ព្រមតាមការតវ៉ា ឬជំទាស់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវណែនាំ និងរំលឹកដល់សមាជិក

គ.ក.ប/គ.ក.រ និងអ្នកដែលមានវត្តមានផ្សេងទៀតក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត អំពីខ្លឹមសារពាក់ព័ន្ធដូចមានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់។

**ឃ.** ប្រសិនបើប្រធាន គ.ក.ប/គ.ក.រ យល់ឃើញថាការតវ៉ា ឬការជំទាស់មិនសមហេតុផល ប្រធាន គ.ក.ប/គ.ក.រ មានសិទ្ធិបដិសេធការតវ៉ា ឬការជំទាស់របស់ភ្នាក់ងារគណបក្សនយោបាយនោះ។

**ឃ.១** ក្នុងការបដិសេធការតវ៉ា ឬការជំទាស់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិសុំឱ្យកត់ត្រាការតវ៉ា ឬជំទាស់នេះក្នុងកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ប្រសិនបើអ្នកប្តឹងយល់ព្រមផ្តិតមេដៃ។

**ឃ.២** ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះ មិនយល់ព្រមផ្តិតមេដៃទេនោះ ប្រធាន គ.ក.ប/គ.ក.រ មិនចាំបាច់កត់ត្រាអំពីការតវ៉ា ឬជំទាស់នោះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតទេ។

**ឃ.៣** ប្រសិនមានការស្នើសុំ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ដល់ភ្នាក់ងារគណបក្សនយោបាយនោះ ដើម្បីប្តឹងបន្តទៅ គឃ.សប ។

**ង.** ការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.ប/គ.ក.រ ត្រូវប្រកាសបន្តដំណើរការបោះឆ្នោត ឬរាប់សន្លឹកឆ្នោតតទៅទៀត។

## ២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

### ២.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅ គឃ.សប

**ក.** ភ្នាក់ងារគណបក្សនយោបាយ ឬតំណាង ដែលមិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ អាចដាក់ពាក្យបណ្តឹងទៅ គឃ.សប ដោយត្រូវធ្វើឡើងជាបន្ទាន់ ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោតផ្សេងទៀតទៅ គឃ.សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

**ខ.** ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្តឹង ត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

**គ.** ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង

២- លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត

៣- ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី

៤- ប្រភេទនៃភាពមិនប្រក្រតី ឬកំហុសឆ្គង ដែលជាកម្មវត្ថុនៃបណ្តឹង

៥- ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ត.រ ឬ ប.ន.ត.រ ដែលត្រូវបានរំលោភ

៦- មនុស្សដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹងនេះ

៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី ប្រសិនបើមាន

៨- សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងទៀត បើមាន

៩- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង បើមាន។

**ឃ.** នៅពេលបានទទួលពាក្យបណ្តឹង សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់ មួយចំនួនមានជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង

២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ យ៉ាងយូរត្រឹមម៉ោង ១១:៣០ នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

**ង.** បន្ទាប់មកសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

**ច.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុហើយឃើញថា៖

**ច.១** ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ម៉ោង ១១:៣០ នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ប្រធាន គឃ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធ

លើពាក្យបណ្តឹងគ្រប់ច្បាប់ថា **"ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុថ្លស់សិទ្ធិក្នុងការប្តឹងមក គយ.សប ។ ដូចនេះ គយ.សប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"**។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទរួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ច.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចក្នុង**ចំណុច គ (ទំព័រ៣០)** ខាងលើ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា **"ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..."** ។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ច.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ម៉ោង ១១:៣០នាទី ព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់**) សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវ

ចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា បោះត្រា គឃ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គឃ.សប ១ (មួយ) ច្បាប់ និងរក្សាទុកក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់។

## ២.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

**ក.** គឃ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង នៅក្នុងអំឡុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងឃុំ សង្កាត់។ ក្នុងករណីចាំបាច់ គឃ.សប អាចបើកការស៊ើបអង្កេតស្រាវជ្រាវ មុននឹងធ្វើការសម្រេចលើពាក្យបណ្តឹង។

**ខ.** ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់មានភស្តុតាងបញ្ជាក់ ដែលអាចឱ្យជឿថា មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និង រាប់សន្លឹកឆ្នោត ដូចចែងក្នុងប្រការ ៨.១៦ នៃ ប.ន.ត.រ ឬភាពមិនប្រក្រតីដូចចែងក្នុងប្រការ ៨.១៧ នៃ ច.ន.ត.រ ប្រធាន គឃ.សប ត្រូវ៖

**ខ.១** ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្តឹង។

**ខ.២** បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ៨.២០ នៃ ប.ន.ត.រ ។

**ខ.៣** អនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាង និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលការអនុវត្តនីតិវិធី។

**គ.** ប្រសិនបើក្នុងការត្រួតពិនិត្យដូចក្នុង**ចំណុច ខ.១** និង**ចំណុច ខ.២ (ទំព័រ៣២)** គឃ.សប មិនឃើញមានភស្តុតាងបញ្ជាក់ថា មានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គឃ.សប ត្រូវប្រជុំសម្រេចបដិសេធលើពាក្យបណ្តឹងនោះ ដោយត្រូវ៖

**គ.១** ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង។

**គ.២** ចុះហត្ថលេខា បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម បានបំពេញរួចប្រគល់ឱ្យអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.៣** ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គឃ.សប ទៅ គធ.ខប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ នេះ។

**គ.៤** ប្រគល់ជូនអ្នកប្ដឹង ឬតំណាងនូវ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ បើគាត់ស្នើសុំ។

**ឃ.** ប្រសិនបើក្នុងការត្រួតពិនិត្យ ដូចក្នុង**ចំណុច ខ.១** និង**ចំណុច ខ.២** (**ទំព័រ៣២**) គឃ.សប បានរកឃើញភស្ដុតាងបញ្ជាក់ថា មានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតនោះ គឃ.សប ត្រូវប្រជុំសម្រេចយល់ព្រមលើពាក្យបណ្ដឹងនោះ ដោយត្រូវ៖

**ឃ.១** ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ យល់ព្រមកែតម្រូវតួលេខលទ្ធផលតាមពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង។

**ឃ.២** ចុះហត្ថលេខា បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទ លើ ទ.១២០៣ ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មបានបំពេញ រួចប្រគល់ឱ្យអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ង. ប្រសិនបើក្នុងការត្រួតពិនិត្យ ដូចក្នុង**ចំណុច ខ.១** និង**ចំណុច ខ.២ (ទំព័រ៣២)** គឃ.សប បានរកឃើញភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គឃ.សប ត្រូវប្រជុំសម្រេចយល់ព្រមតាមពាក្យបណ្ដឹងនោះ ដោយត្រូវ ៖

**ង.១** ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យបំពេញ ទ.១២០៣ យល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង។

**ង.២** ចុះហត្ថលេខា បោះត្រា គឃ.សប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មបានបំពេញ រួចប្រគល់ឱ្យអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គជ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ង.៣** ជម្រាបអ្នកប្ដឹង ឬតំណាងថា គឃ.សប នឹងធ្វើរបាយការណ៍ និងលើកយោបល់ស្ដីពីករណីនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និង ទ.១២០៣ ជូន គជ.ខប ដើម្បីពិនិត្យសម្រេច។

## ៣. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គជ.ខប

### ៣.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គជ.ខប

ក. ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលទទួលបានការអនុញ្ញាតឱ្យសង្កេតមើលការបោះឆ្នោតនៃឃុំ សង្កាត់ណាមួយ ឬតំណាង ដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងតវ៉ា ដូចមានចែងក្រោម**ចំណុច គ** (**ទំព័រ៣២**) មានសិទ្ធិប្ដឹងតវ៉ាទៅ គជ.ខប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គឃ.សប ។

ខ. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

គ. ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួន ដូចក្នុង**ចំណុច គ (ទំព័រ៣០)** ។

ឃ. បន្ទាប់ពីបានទទួលពាក្យបណ្តឹង មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹង ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង

២- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ យ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គឃ.សប ។

ង. បន្ទាប់មកសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

ច. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុហើយឃើញថា៖

ច.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ យ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គឃ.សប ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា "**ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុផ្តស់សិទ្ធិក្នុងការប្តឹងមក គធ.ខប ។ ដូចនេះ គធ.ខប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"។** បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ច.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចក្នុង**ចំណុច គ (ទំព័រ៣០)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុង

កំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា "**ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..**"។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ច.៣** ពាក្យបណ្តឹងគោរពរយៈពេលកំណត់យ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គឃ.សឃ មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់**) សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា បោះត្រា គធ.ឃប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គធ.ឃប ១ (មួយ) ច្បាប់ និងរក្សាទុកក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់។

## ៣.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹងនៅ គធ.ឃប

**ក.** គធ.ឃប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០២ ។ ក្នុងករណីចាំបាច់ គធ.ឃប អាចបើកការស៊ើបអង្កេតស្រាវជ្រាវ មុននឹងសម្រេចលើពាក្យបណ្តឹង។

**ខ.** ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ឃប ដែលធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានពាក្យបណ្តឹង ត្រូវអនុវត្តបន្ថែមតាមលក្ខខណ្ឌដូចខាងក្រោម៖

**ខ.១** ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវត្រួតពិនិត្យជាមុននូវសេចក្តីសម្រេចរបស់ គឃ.សឃ លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍របស់ គឃ.សឃ ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បី

ត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន) និងពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់នោះ ដែលបានដាក់នៅ គធ.ឃប ហើយត្រូវស្នើសុំយោបល់សម្រេចពី គធ.ឃប អំពីការអនុញ្ញាតឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" នៃ ការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

**ខ.២** ផ្អែកតាមឯកសារខាងលើ ក្នុងករណីគ្មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គធ.ឃប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតឡើយ។

**ខ.៣** ផ្អែកតាមឯកសារខាងលើ ក្នុងករណីមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោត គធ.ឃប ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

**ខ.៤** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើនៅចំពោះមុខអ្នកប្ដឹង ឬតំណាង ឬតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។

**គ.** ប្រសិនបើ គធ.ឃប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្នុង**ចំណុច ខ.២ (ទំព័រ៣៧)** គធ.ឃប ត្រូវអនុវត្តនីតិវិធីដូចចែងក្នុងចំណុច ៨.២៧.១ ដល់ ៨.២៧.៤ នៃ ប.ន.ត.រ ។

**ឃ.** ប្រសិនបើ គធ.ឃប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្នុងចំណុច **ខ.៣ (ទំព័រ៣៧)** ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តនីតិវិធីចំណុច ៨.២៧.១ និង ៨.២៧.៣ នៃ ប.ន.ត.រ ហើយបន្ទាប់មកប្រធានក្រុមត្រូវ៖

ឃ.១ បង្គាប់ជំនួយការឱ្យនាំយកស្បោង "គ មានបណ្តឹង" នៃឃុំ សង្កាត់ពាក់ព័ន្ធពីបន្ទប់រក្សាស្តុក មកដាក់នៅលើតុចំពីមុខប្រធានក្រុម។

ឃ.២ បើកស្បោង "គ" នោះ ដកយកស្បោង "ខ" ចេញមកក្រៅ រួចបើក និងដកយកកញ្ចប់សុវត្ថិភាព "ក" មកដាក់នៅលើតុ។

ឃ.៣ បើកកញ្ចប់សុវត្ថិភាព "ក" រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុង មកដាក់ដោយឡែកពីគ្នានៅលើតុខាងមុខគាត់។

ឃ.៤ ប្រគល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ឱ្យទៅលេខាធិការ សម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

ឃ.៥ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធីដូចមានចែងចំណុច ង (ទំព័រ៣៨)។

ង. នៅពេលមាន ទ.១១០១ ទ.១១០២ និង ទ.១១០៨ ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ត្រូវចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៃការិយាល័យនោះ តាមលំនាំនីតិវិធីដូចមានចែងក្រោមចំណុច ៨.២០.២ នៃ ប.ន.ត.រ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាក្នុងកម្មវត្ថុនៃពាក្យបណ្តឹងពាក់ព័ន្ធ។

ច. បន្ទាប់ពីបើកកញ្ចប់សុវត្ថិភាព "ក" នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ដូចមានចែងក្រោមចំណុច ឃ និង ង (ទំព័រ៣៧ ដល់ទំព័រ៣៨) រួចរាល់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងអនុវត្តដូចខាងក្រោម៖

ច.១ ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល។ ក្នុងរបាយការណ៍នេះត្រូវតែមានលើកយោបល់ស្នើសុំ គធ.ខប ពិនិត្យសម្រេចតាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស៖

- យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ
- យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ករណីរកឃើញកំហុសឆ្គងក្នុងការគណនាលេខ ឬ
- ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (រាប់សន្លឹកឆ្នោតឡើងវិញ ឬបោះឆ្នោតសាជាថ្មី)។

ច.២ ចារលើរបាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ដូចចែងក្នុង**ចំណុច ច.១ (ទំព័រ៣៩)**។

ច.៣ ដាក់របាយការណ៍ ដូចចែងក្នុង**ចំណុច ច.១ (ទំព័រ៣៩)** សេចក្តីសម្រេចរបស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន) ភ្ជាប់ទៅនឹងតារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារពាក់ព័ន្ធដែលក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ជូន គធ.ខប ពិនិត្យសម្រេចតាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដូចបញ្ជាក់ក្នុងចំណុច ៨.២៧.១.៩ នៃ ប.ន.ត.រ ។

**ច.៤** ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក និង ស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព "ក" តាមលំនាំដើម។

**ច.៥** ដាក់កញ្ចប់សុវត្ថិភាព "ក" ទៅក្នុងស្បោង "ខ" រួចចងភ្ជិត និង ដាក់ស្បោង "ខ" ទៅក្នុងស្បោង "គ មានបណ្តឹង" តាមលំនាំ ដើម និងចាក់សោឃ្លុំមានលេខ ដែលត្រូវនាំយកទៅរក្សាទុក នៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

**ឆ.** ផ្អែកលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ស្តីពីការបើក កញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារ បោះឆ្នោត និងសន្លឹកឆ្នោត និងសំណុំឯកសារ ដូចចែងក្នុង**ចំណុច ច.៣ (ទំព័រ៣៩)** ខាងលើ ព្រមទាំងផ្អែកលើពាក្យបណ្តឹងតវ៉ា ឬ ពាក្យបណ្តឹងជំទាស់ដែល គធ.ខប បានទទួល គធ.ខប ត្រូវប្រជុំ សម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ ដោយត្រូវអនុវត្តតាម**ចំណុច ជ ឈ** និង **ញ (ទំព័រ៤០ ដល់ទំព័រ៤១)**។

**ជ.** ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការ បោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុង ឃុំ សង្កាត់ គធ.ខប ត្រូវចារយល់ព្រមលើសេចក្តីសម្រេចរបស់ គឃ.សប ដែលបានទទួលយកលទ្ធផលនៃការបោះឆ្នោត និងចារបដិសេធពាក្យ បណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលបានដាក់នៅ គធ.ខប ឬចារ បដិសេធលើសេចក្តីសម្រេចរបស់ គឃ.សប ដែលយល់ព្រមកែតម្រូវ លទ្ធផលនៃការបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុង ឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវអនុវត្តនីតិវិធីដូចមានចែងចាប់ពី ចំណុច ៨.២៨.១១.១ ដល់ ៨.២៨.១១.៨ នៃ ប.ន.ត.រ ។

**ឈ.** ប្រសិនបើ គធ.ខប សម្រេចយល់ព្រមកែតម្រូវលទ្ធផលនៃការបោះ-ឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬលទ្ធផលនៃការបោះឆ្នោត នៅឃុំ សង្កាត់ គធ.ខប ត្រូវចារបដិសេធលើ ទ.១២០៣ របស់ គឃ.សប

ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងចារយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដែលបានដាក់នៅ គធ.ខប ។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវអនុវត្តនីតិវិធីដូចមានចែងចាប់ពីចំណុច ៨.២៨.១២.១ ដល់ ៨.២៨.១២.៦ នៃ ប.ន.ត.រ ។

**ញ.** ប្រសិនបើ គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវចារយល់ព្រមលើ ទ.១២០៣ របស់ គឃ.សប ដែលបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬចារបដិសេធលើ ទ.១២០៣ របស់ គឃ.សប ដែលយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងចារយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែលបានដាក់នៅ គធ.ខប ។ ក្នុងករណីនេះប្រធាន គធ.ខប ត្រូវអនុវត្តនីតិវិធីដូចមានចែងចាប់ពីចំណុច ៨.២៨.១៣.១ ដល់ ៨.២៨.១៣.៨ នៃ ប.ន.ត.រ ។

**ដ.** គធ.ខប ត្រូវបញ្ជូន ទ.១២០៣ ដែលសម្រេចព្យួរជាបណ្ដោះអាសន្នលទ្ធផលនៃការបោះឆ្នោត និងសម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលចេញ ទ.១២០៣ ។

## ៤. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ៤.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

**ក.** ភ្នាក់ងារគណបក្សនយោបាយ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងរបស់គាត់ពាក់ព័ន្ធនឹងកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតី ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ៨.២៨.១១.៥ នៃ ប.ន.ត.រ មានសិទ្ធិប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប ដែលបដិសេធពាក្យបណ្ដឹង ។

**ខ.** អ្នកប្ដឹង ឬតំណាងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃលើ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ដែលក្នុងនោះត្រូវផ្ដល់ព័ត៌មានចាំបាច់ដូចក្នុង**ចំណុច គ (ទំព័រ៣០)**។

**គ.** នៅពេលបានទទួលពាក្យបណ្ដឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពរយៈពេលកំណត់ ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ឃប ។

**ឃ.** បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រា រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។

**ង.** បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុហើយឃើញថា៖

**ង.១** ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់យ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ឃប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា **"ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ ដែលជាហេតុថ្លស់សិទ្ធិក្នុងការប្ដឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាច ទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"** ព្រមទាំងចុះហត្ថលេខាបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ង.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចក្នុង**ចំណុច គ (ទំព័រ៣០)** ខាងលើ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេល កំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ថា **"ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..."** ព្រមទាំងចុះហត្ថលេខាបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ង.៣ ពាក្យបណ្ដឹងគោរពរយៈពេលកំណត់យ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់ និង ទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ៤.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្ដឹង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០២ ។ ក្នុងករណីចាំបាច់ គ.ជ.ប អាចបើកការស៊ើបអង្កេតស្រាវជ្រាវ មុននឹងធ្វើការសម្រេចលើពាក្យបណ្ដឹង។

ខ. ក្រោយពីទទួលបានពាក្យបណ្ដឹងនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ អំពីករណីនៃពាក្យបណ្ដឹង ដោយភ្ជាប់ពាក្យបណ្ដឹងតវ៉ាដែលបានទទួល និង ទ.១២០៣ របស់ គធ.ខប បដិសេធលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដែលត្រូវដកចេញពីកញ្ចប់ "ឃ ពិសេស" និងដើម្បីសុំការណែនាំពី គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។ ផ្អែកតាមការណែនាំរបស់ គ.ជ.ប អគ្គលេខាធិការ ត្រូវចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងបណ្ដឹងនោះ នៅចំពោះមុខតំណាងគណបក្សពាក់ព័ន្ធ អ្នកប្ដឹង ឬតំណាង និងអ្នកសង្កេតការណ៍។

គ. ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវធ្វើរបាយការណ៍យល់ព្រមទទួលយក ឬកែតម្រូវតួលេខ (កំហុសក្នុងការគណនា ឬរាប់សន្លឹកឆ្នោតឡើងវិញ) ឬបដិសេធលទ្ធផលនៃការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ ឬទាំងនោះ។ ប្រធានក្រុមត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ឬ/និងរបាយការណ៍ខាងលើ ត្រូវចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមពាក់ព័ន្ធ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច។

ឃ. ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមពាក្យបណ្ដឹង ដោយធ្វើការកែតម្រូវតួលេខលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ គ.ជ.ប ត្រូវប្រគល់សំណុំឯកសារដែលបានសម្រេចនេះ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ។

ង. ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមពាក្យបណ្ដឹង ដោយបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់ គ.ជ.ប ត្រូវចាត់

ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃចេញ ទ.១២០៣ សម្រេចបដិសេធ។

**ច.** ក្នុងករណីដែល គ.ជ.ប សម្រេចបដិសេធពាក្យបណ្តឹង ដោយយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ចំណុះរាជធានី ខេត្ត គ.ជ.ប ត្រូវប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

**ឆ.** សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចចុងក្រោយ នៅមុនការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

## ៥. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទង នឹងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត



# ផ្នែកទី ៥
# បណ្តឹងទាក់ទងនឹងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ផ្នែកទី ៥ នៃសៀវភៅណែនាំនេះ មានគោលដៅណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង យ៉ាងយូរ បន្ទាប់ពីការប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ឬតំណាង អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន ។

## ១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ១.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

**ក.** គណបក្សនយោបាយ ឬតំណាងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចក្នុង**ចំណុច គ (ទំព័រ៣០)**។

**ខ.** នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីការប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

**គ.** បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់នេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុហើយឃើញថា៖

ឃ.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា **"ពាក្យបណ្តឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដែលជាហេតុផ្តល់សិទ្ធិក្នុងការប្តឹងមក គ.ជ.ប ។ ដូចនេះ គ.ជ.ប មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ"** ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចក្នុង**ចំណុច គ (ទំព័រ៣០)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹងឬតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា **"ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ..."** ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីប្រកាសលទ្ធផលបណ្តោះអាសន្ននៃការ

បោះឆ្នោត មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់**) មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកពេលដោះស្រាយ ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈនៅទីស្ដីការ គ.ជ.ប ១ (មួយ) ច្បាប់។

## ១.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

**ក.** ពាក្យបណ្ដឹងដែលមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានគ្រប់គ្រាន់ គ.ជ.ប ត្រូវសម្រេចលើបណ្ដឹងតវ៉ា ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួល ទ.១២០២។

**ខ.** ក្នុងការដោះស្រាយ គ.ជ.ប ត្រូវចាត់អគ្គលេខាធិការ ដែលមាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងនាយកដ្ឋានប្រតិបត្តិការជាជំនួយការ រៀបចំឱ្យមានឯកសារដូចខាងក្រោម៖

**ខ.១** ប្រមូលផ្ដុំរាល់ពាក្យបណ្ដឹងអំពីភាពមិនប្រក្រតី ដែលកើតមានឡើងនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដែលមានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ។

**ខ.២** ប្រមូលផ្ដុំរាល់សម្រង់សេចក្ដីសម្រេចលើពាក្យបណ្ដឹង អំពីភាពមិនប្រក្រតី ដែលកើតមានឡើងនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ។

**ខ.៣** ប្រមូលផ្ដុំរាល់ ទ.១១០១ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្តពាក់ព័ន្ធ។

**ខ.៤** កំណត់ហេតុសាកសួរយកព័ត៌មានបន្ថែម ពីគណបក្សនយោបាយ ឬតំណាង។

**ខ.៥** ឯកសារ ភស្តុតាងនានា ដែលដាក់ភ្ជាប់ជាមួយនឹងពាក្យបណ្ដឹង។

**ខ.៦** ចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន ចុះអង្កេតស្រាវជ្រាវដល់ទីកន្លែងករណីចាំបាច់។

**គ.** បន្ទាប់មកអគ្គលេខាធិការ ត្រូវណែនាំនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មឱ្យត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារ ដូចបានរៀបរាប់ក្នុង **ចំណុច ខ (ទំព័រ៤៩)** ព្រមទាំងធ្វើរបាយការណ៍ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងលើកយោបល់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការអំពីការសម្រេចទទួលយក ឬបដិសេធលើពាក្យបណ្តឹង។

**ឃ.** គ.ជ.ប ត្រូវសម្រេចបដិសេធលើពាក្យបណ្តឹងតវ៉ា ប្រសិនបើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ដូចមានចែងក្នុង**ចំណុច គ (ទំព័រ៥០)** គ.ជ.ប រកឃើញថា៖

**ឃ.១** ពុំមានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់អំពីការកើតមានឡើងនូវភាពមិនប្រក្រតីធ្ងន់ធ្ងរដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផល នៃការបោះឆ្នោត ឬ

**ឃ.២** ពុំមានការតវ៉ា ឬការជំទាស់អំពីភាពមិនប្រក្រតីណាមួយនៅការិយាល័យបោះឆ្នោត ឬ/និងការិយាល័យរាប់សន្លឹកឆ្នោត ឬ

**ឃ.៣** ពុំមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលត្រូវបានដាក់ទៅ គឃ.សប យ៉ាងយូរត្រឹមម៉ោង ១១:៣០ នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ឬមានពាក្យបណ្តឹងដែរ ប៉ុន្តែត្រូវបាន គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប សម្រេចបដិសេធ។

**ង.** ក្នុងករណី គ.ជ.ប សម្រេចបដិសេធ ដូចក្នុង**ចំណុច ឃ (ទំព័រ៥០)** ប្រធាន គ.ជ.ប ត្រូវអនុវត្តនីតិវិធីដូចមានចែងចាប់ពីចំណុច ៨.៣៩.៦.១ ដល់ ៨.៣៩.៦.៥ នៃ ប.ន.ត.រ ។

**ច.** គណបក្សនយោបាយ ឬតំណាង ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបាន ទ.១២០៣ ។

**ឆ.** គ.ជ.ប ត្រូវសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ដោយត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រសិនបើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ដូចចែងក្នុង**ចំណុច គ (ទំព័រ៥០)** គ.ជ.ប រកឃើញថា មានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់អំពីការកើតមានឡើងនូវភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត និងមានបណ្តឹង

អំពីភាពមិនប្រក្រតីកើតមាននៅការិយាល័យបោះឆ្នោត ឬនិងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវបានដាក់នៅ គឃ.សប ត្រឹមម៉ោង ១១:៣០ (ដប់មួយសាមសិប) នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។ ក្នុងករណីនេះ ប្រធាន គ.ជ.ប ត្រូវអនុវត្តនីតិវិធីដូចមានចែងចាប់ពីចំណុច ៨.៣៩.៧.១ ដល់ ៨.៣៩.៧.៥ នៃ ប.ន.ត.រ ។

**ជ.** គ.ជ.ប ត្រូវចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃចេញ ទ.១២០៣ ដែលសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោត។

## ២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ២.១ នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមួយផ្នែក ឬទាំងអស់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ឬអ្នកប្ដឹងតវ៉ា ឬតំណាង ដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួល ទ.១២០៣ ។

**ខ.** នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ២.២ នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើបណ្ដឹងតវ៉ាដោយបើកសវនាការក្នុងរយៈពេលពី ១០ (ដប់) ថ្ងៃ ទៅ ២០ (ម្ភៃ) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

**ខ.** នីតិវិធីដោះស្រាយបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**គ.** សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា។

## ៣. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត



# ផ្នែកទី៦
# នីតិវិធីអនុវត្តសេចក្ដីសម្រេចស្ដាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់

ការអនុវត្តសេចក្ដីសម្រេចស្ដាពរដាក់ទណ្ឌកម្មពិន័យជាប្រាក់ទៅលើជនល្មើស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

**ក.** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ជាអ្នកទទួលខុសត្រូវរៀបចំសំណុំឯកសារអនុវត្តសេចក្ដីសម្រេចស្ដាពរ និងលើកសំណើតាមរយៈអគ្គលេខាធិការដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

**ខ.** តាមរយៈការសម្រេចឱ្យអនុវត្តសេចក្ដីសម្រេចស្ដាពរ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចាត់វិធានការជូនដំណឹងទៅជនដែលត្រូវពិន័យ ឱ្យចូលខ្លួនមកអនុវត្តសេចក្ដីសម្រេចដាក់ទណ្ឌកម្មពិន័យជាប្រាក់នោះដោយស្ម័គ្រចិត្ត ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្ដីបង្គាប់។

**គ.** បើដល់ពេលកំណត់ ជនដែលត្រូវពិន័យមិនព្រមបង់ប្រាក់ពិន័យតាមសេចក្ដីជូនដំណឹងទេនោះ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរៀបចំរបាយការណ៍ និងលើកសំណើតាមរយៈអគ្គលេខាធិការដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

**ឃ.** ក្នុងករណីដែល គ.ជ.ប យល់ឃើញថាគ្មានស្ថានភាពណាមួយដែល គ.ជ.ប ត្រូវពន្យារពេល ឬបន្ធូរបន្ថយ ឬលើកលែងទណ្ឌកម្មពិន័យជាប្រាក់ ឬរំលត់ការដាក់ទណ្ឌកម្មទេនោះ គ.ជ.ប អាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ គ.ជ.ប ទារប្រាក់ពីជនដែលត្រូវពិន័យជូន គ.ជ.ប។

**ង.** ប្រាក់ពិន័យដែលទទួលបាន ត្រូវដាក់ចូលជាថវិកាជាតិ។

# ជំពូកទី៣
# សមត្ថកិច្ច នីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការ ដោះស្រាយពាក្យបណ្ដឹង

## ផ្នែកទី ១
## សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

គយ.សប គធ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្ដឹង ដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គយ.សប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច គធ.ខប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬ/និងបើកសវនាការ និង គ.ជ.ប ប្រជុំសម្រេច ឬបើកសវនាការលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង ដូចបានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរួមមានដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដំណាក់កាលឃោសនាបោះឆ្នោត និងដំណាក់កាលនៃការបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### ១. សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គយ.សប ឬ គធ.ខប ឬ គ.ជ.ប ។

#### ១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គយ.សប

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ដែលចាត់តាំងដោយ គយ.សប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេចរបស់ខ្លួន ស្របតាមនីតិវិធីដោះស្រាយពាក្យបណ្ដឹង ដូចមានចែងក្នុង**ចំណុច ២.១ (ទំព័រ៥៦)** នៃសៀវភៅណែនាំនេះ។

ប្រធាន និងសមាជិក គឃ.សប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា **ក្រុមប្រឹក្សាប្រជុំផ្សះផ្សា** ឬបានចាត់តាំងឱ្យចូលរួម ប្រជុំសម្រេចហៅថា **ក្រុមប្រឹក្សាប្រជុំសម្រេច។** សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ក្រុមប្រឹក្សាប្រជុំសម្រេច នៃ គឃ.សប រួមមាន៖

- ប្រធាន គឃ.សប ឬតំណាងជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច
- អនុប្រធាន និងសមាជិក គឃ.សប ជាសមាជិក
- សមាជិក គឃ.សប ១ (មួយ) រូប ទទួលភារកិច្ចបន្ថែមជាលេខាធិការ។

កូរ៉ុម និងលក្ខខណ្ឌសុពលភាព នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច នៃ គឃ.សប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក គឃ.សប ទាំងមូល។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មិនត្រូវមានសំឡេងអនុបវាទឡើយ។

### ១.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ដែលចាត់តាំងដោយ គធ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ និងការសម្រេចរបស់ខ្លួន តាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា **ក្រុមប្រឹក្សាប្រជុំផ្សះផ្សា** ឬដែលបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេចហៅថា **ក្រុមប្រឹក្សាប្រជុំសម្រេច** ឬដែលបានចាត់តាំងឱ្យចូលរួមសវនាការហៅថា **ក្រុមប្រឹក្សាជំនុំជម្រះ។** សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី គធ.ខប ដែលត្រូវបានចាត់តាំង ជាលេខាធិការ។

កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិក គធ.ខប ទាំងមូល។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មិនត្រូវមានសំឡេងអនុបវាទឡើយ។

### ១.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយពាក្យបណ្តឹងហៅថា **ក្រុមប្រឹក្សាជំនុំជម្រះ**។ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ជាគណៈលេខាធិការសវនាការ។

លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ៥០ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ។

## ២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

### ២.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប

ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មានសិទ្ធិអំណាចកោះហៅគូភាគី ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។ ដោយឡែកការប្រជុំសម្រេចអាចកោះហៅសាក្សីបាន។

ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច អាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ចំពោះជនណា ឬជនទាំងឡាយណា

ដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេចដោះស្រាយបណ្ដឹង ដូចក្នុងឧបសម្ព័ន្ធទី៣ ស្ដីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្ដឹង។

### ២.២ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប

ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសិទ្ធិអំណាចកោះហៅគូភាគី ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។ ដោយឡែកក្នុងការប្រជុំសម្រេច ឬសវនាការ អាចកោះហៅសាក្សីបាន។

ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬអង្គសវនាការ ហើយមានសិទ្ធិបណ្ដេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្ដឹង ដូចក្នុងឧបសម្ព័ន្ធទី៣ ស្ដីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្ដឹង។

### ២.៣ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្ដីក្នុងករណីដែលមានបណ្ដឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្ដឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្ដឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ប៉ុន្តែក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះ ចេញសេចក្ដីសម្រេចជាស្ថាពរហើយ អ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានពាក្យបណ្ដឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយ ដោយចាត់ទុកជាករណីថ្មីទៀត។

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅគូភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

គ.ជ.ប មានសិទ្ធិធ្វើការស៊ើបអង្កេតលើករណីមាន ឬគ្មានបណ្តឹង ក្នុងគោលបំណង ឱ្យមានការគោរព ច.ប.ត.រ និង ប.ន.ត.រ និងដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ក្នុងពេលសវនាការ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការដោះស្រាយបណ្តឹង ដូចក្នុងឧបសម្ព័ន្ធទី ៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង។

## ផ្នែកទី ២
## សិទ្ធិ និងភារកិច្ចដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី

### ១. សិទ្ធិ និងភារកិច្ចរបស់គូភាគី

ក្នុងករណីគូភាគី មានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬអ្នកការពារក្ដី ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងពាក្យបណ្ដឹងឱ្យចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ មុនពេលបើកអង្គប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ។

គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ដោយមានចុះហត្ថលេខា ឬផ្ដិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃអ្នកតំណាងនោះ (**តំណាងត្រូវតែជានីតិជន**[៣])។

លិខិតប្រគល់សិទ្ធិនេះត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ យ៉ាងតិច ២ (ពីរ) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការ។

ដើមបណ្ដឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថាមានប្រយោជន៍ដល់ខ្លួន ជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

---

[៣] ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ

គូភាគីមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ត.រ និង ប.ន.ត.រ ។

## ២. សិទ្ធិ និងភារកិច្ចរបស់ដើមបណ្តឹង

ដើមបណ្តឹងអាចដកពាក្យបណ្តឹងទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ.សប ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។

ការដកពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គឃ.សប ឬ គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ហើយពាក្យនោះត្រូវបានលើកចោលតាមការស្នើសុំ។

ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយចេញ ទ.១២០៣។

ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ ហើយត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន។

ដើមបណ្តឹង ឬ/និងជនរងគ្រោះមានវិសមិតភាព[៤] រវាងឋានៈជាដើមបណ្តឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្តល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹងបានដែរ។

## ៣. សិទ្ធិ និងភារកិច្ចរបស់ចុងចម្លើយ

ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាង ដែលបានទទួលសិទ្ធិ ហើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សី ដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន។

ចុងចម្លើយអាចបង្ហាញភស្តុតាង ជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាង ដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

## ៤. សិទ្ធិ និងភារកិច្ចរបស់មេធាវី ឬតំណាង

មេធាវី ឬតំណាង មិនអាចធ្វើការប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀត ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

ដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់ភាគី អាចស្នើសុំឱ្យ គយ.សប ឬ គជ.ឃប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។

## ៥. សិទ្ធិ និងភារកិច្ចរបស់សាក្សី

សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវចំពោះមុខច្បាប់ អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (**ខ្លឹមសារសម្បថមានក្នុងឧបសម្ព័ន្ធទី៤ ស្តីពីនីតិវិធី និងខ្លឹមសារនៃសម្បថ**)។

---

[៤] ភាពដែលមិនអាចមាន ឬប្រកបកិច្ចការចូលគ្នាបាន

សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យចូលមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។ ហើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ។

សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

# ផ្នែកទី ៣
# នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង (មានចែងក្នុងឧបសម្ព័ន្ធទី៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង)។

## ១. ប្រភេទសវនាការ

ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។

**សវនាការសង្ខេប** ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថា មានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

**សវនាការតទល់** ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ។

**សវនាការសួរដេញដោល** ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គឺភាសាខ្មែរ។

ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

## ៣. ពេលវេលាដោះស្រាយពាក្យបណ្តឹង

អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងរសៀល ចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី។ ក្នុងករណីចាំបាច់ អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។

ក្នុងករណីដែលថ្ងៃកំណត់ដោះស្រាយបណ្តឹង និងសម្រេចលើបណ្តឹងចំថ្ងៃបុណ្យជាផ្លូវការ អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការត្រូវលើកទៅថ្ងៃបន្ទាប់។

ក្នុងកម្មវិធីមួយពេលនៃការបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬជំនុំជម្រះច្រើនករណីនៃបណ្តឹងបាន។

## ៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬបើកសវនាការ

### ៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គឃ.សប

គឃ.សប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេចនៅថ្នាក់ គឃ.សប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចចែងនៅក្នុង ច.ប.ត.រ និង ប.ន.ត.រ ។

គឃ.សប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច។

### ៤.២ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការនៅ គធ.ខប

គធ.ខប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬបើកសវនាការនៅថ្នាក់ គធ.ខប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ។

លគធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកប្រជុំផ្សះផ្សា ឬសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងប្រជុំផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកសវនាការ (ករណីពាក្យបណ្តឹងដែលអាចនាំឱ្យមានការផាកពិន័យ) ឬប្រជុំសម្រេច ឬបើកសវនាការ។

### ៤.៣ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ។

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ។

## ៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ

លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការមានភារកិច្ចដូចខាងក្រោម៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅធ្វើសម្បថ (**ករណីប្រជុំសម្រេច ឬសវនាការ**)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរ នៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការដែលត្រូវស្រង់វត្តមានសាក្សី។

- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោយដៃ ឬដោយកុំព្យូទ័រ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ មិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខាលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគីពាក់ព័ន្ធ ។
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធ តាមការបង្គាប់ពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- រៀបចំ ទ.១២០៣ រួចចុះហត្ថលេខា រួចដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ។
- អញ្ជើញភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្តិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

## ៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

នៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ

ឬស្នាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។

ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ៖

ទី១. ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ទី២. ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ

ទី៣. បង្គាប់លេខាធិការអង្គប្រជុំសម្រេច លេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ឱ្យរាយការណ៍អំពីវត្តមានដើមបណ្តឹង ចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ)។

មុននឹងចាប់ផ្តើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្តឹងថា **តើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្តឹង ឬមានការកែប្រែឬទេ?** ប្រសិនបើ៖

- ដើមបណ្តឹងឆ្លើយថាខ្លួនដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់ឱ្យលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ កត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្តឹងផ្តិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សា អាចផ្សះផ្សារឿងក្តីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តទៅប្រជុំសម្រេច ឬជំនុំជម្រះរឿងក្តីផ្សេងទៀត (ប្រសិនបើមាន)។
- ដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្តើមដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។

ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សីចុងចម្លើយ និង អ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្តឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្តី សួរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយមុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬការសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្តឹងដកពាក្យបណ្តឹងពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយរួចហើយ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ ។

ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

## ៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតជូនដំណឹងហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកបណ្តឹងចោល ដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេនោះ ក្រុមប្រឹក្សាប្រជុំ

សម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច។

ប្រសិនបើភាគីដើមបណ្តឹងស្លាប់ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវលុបបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់អមដំណើរជាមួយ ដើម្បីបញ្ជូន ទ.១២០៣ ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយក ទ.១២០៣ នោះ លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើ ទ.១២០៣ នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា "ដើមបណ្តឹង ឬតំណាង ឬចុងចម្លើយ ឬតំណាងមិនព្រមទទួលយក ទ.១២០៣" ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយដើម្បីបញ្ជាក់ថា ភាគីវិវាទពិតជាមិនព្រមទទួលយក ទ.១២០៣ រួចបិទ ទ.១២០៣ នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីវិវាទ ហើយចាត់ទុកថាភាគីវិវាទបានទទួល ទ.១២០៣ រួចហើយ។

## ៤. មធ្យោបាយបង្ហាញភស្តុតាង

មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការនេះ។

ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរព ច.ប.ត.រ និង ប.ន.ត.រ ។

ជនណាបានប្រព្រឹត្តការក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន។

## ៩. ការបំពេញ និងការប្រើប្រាស់ ទ.១២០៣

ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ហើយចុះហត្ថលេខាដោយលេខាធិការ អង្គប្រជុំប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច។ ការបំពេញ ទ.១២០៣ នៅ គឃ.សប ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់បណ្ដឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់បណ្ដឹងជំទាស់ ដើម្បី៖

- ជូន ឬផ្ញើជូនសាមីអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្ដឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គជ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្ដីសម្រេចនេះ ត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃបណ្ដឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គជ.ខប ត្រូវធ្វើឡើងដោយផ្អែកតាមលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ហើយត្រូវចុះហត្ថលេខាដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេចនៃ គជ.ខប ។

ការបំពេញ ទ.១២០៣ នៅ គជ.ខប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់បណ្ដឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់បណ្ដឹងជំទាស់ ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់

- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ **(ចំពោះបណ្តឹងជំទាស់)** ជាបន្ទាន់
- ផ្ញើជូន គឃ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់បណ្តឹងជំទាស់ ដើម្បីៈ

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ **(ចំពោះបណ្តឹងជំទាស់)** ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច។ ទ.១២០៣ ត្រូវប្រគល់ជូនភាគីវិវាទភ្លាមៗបន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួល ទ.១២០៣ នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្តែង។ ក្នុងករណីៈ

- ភាគីវិវាទណាមួយបដិសេធមិនព្រមទទួលយក ទ.១២០៣ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់។
- ភាគីវិវាទជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវបញ្ជូន ទ.១២០៣ ដោយមានដីកាអម ទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ ។ កាលបរិច្ឆេទនៃការទទួលដីកាអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួល ទ.១២០៣។

## ១០. ទម្រង់ផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ

គឃ.សប ឬ គធ.ខប ឬ គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ មានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ កំណត់ហេតុសាកសួរ និងកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និង គ.ជ.ប ។

លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ រួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និង រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

កំណត់ហេតុសាកសួរ អាចធ្វើឡើងដោយដៃ ឬដោយវាយកុំព្យូទ័រ។

កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធទៅនឹងបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា។

កំណត់ហេតុប្រជុំសម្រេច និងកំណត់ហេតុសវនាការ ត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធទៅនឹងបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ច្បាប់ថតចម្លងនៃសេចក្តីសម្រេចនេះ អាចផ្តល់ជូនគូភាគីបានប្រសិនបើមានការស្នើសុំ។

# ឧបសម្ព័ន្ធទី ១

## ទម្រង់បែបបទពាក្យបណ្ដឹង ( ឧ.១២០២ )

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ពាក្យបណ្ដឹង (ឧ.១២០២)

I. **សម្រាប់អ្នកប្ដឹង**

១. អត្តសញ្ញាណអ្នកប្ដឹង

- ឈ្មោះអ្នកប្ដឹង ៖ ________ ភេទ ____ ថ្ងៃខែឆ្នាំកំណើត ________
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ ____ ផ្លូវ ____ ភូមិ ____ ឃុំ សង្កាត់ ________
  ក្រុង ស្រុក ខណ្ឌ ________ រាជធានី ខេត្ត ________
- តួនាទី/មុខងារ ៖ ☐ប្រជាពលរដ្ឋ ☐ភ្នាក់ងារគណបក្សនយោបាយ ________
  ☐ផ្សេងៗ ________ ទូរស័ព្ទទាក់ទង ________

២. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្ដឹង

| រាជធានី ខេត្ត | | | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | | | | លេខកូដការិយាល័យ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| លេខកូដ | | | | លេខកូដ | | | | | | | |

៣. កម្មវត្ថុនៃបណ្ដឹង ៖ ................................................

................................................

................................................

................................................

៤. មូលហេតុនៃការប្ដឹង ៖ ................................................

................................................

................................................

................................................

................................................

................................................

................................................

................................................(ករណីត្រូវការបន្ថែមសូមសរសេរនៅខាងខ្នង)

៥. កាលបរិច្ឆេទ ៖ ........../........../..........

៦. ហត្ថលេខា ឬស្នាមមេដៃអ្នកប្ដឹង (ប្រសិនបើអ្នកជាតំណាង ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរភ្ជាប់មកជាមួយ)

II. **សម្រាប់មន្ត្រីទទួលបន្ទុកការិយាល័យបោះឆ្នោត**

ថ្ងៃ ________ ខែ ____ ឆ្នាំ ________ ព.ស ____

________ ថ្ងៃទី ____ ខែ ____ ឆ្នាំ ____

| លេខពាក្យបណ្ដឹង | កាលបរិច្ឆេទទទួលពាក្យបណ្ដឹង | កាលបរិច្ឆេទប្រជុំសម្រេច ឬបើកសវនាការ |
|---|---|---|
| | ........../........../.......... | |
| .......... | ម៉ោង.......... ព្រឹក☐, រសៀល☐ | ........../........../.......... |

**ហត្ថលេខា និងត្រា**

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញដោយអ្នកប្ដឹងតវ៉ា ឬប្ដឹងជំទាស់

## ឧបសម្ព័ន្ធទី ២
## ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ឧ.១២០៣)

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

### សម្រង់សេចក្តីសម្រេច (ឧ.១២០៣)

១. លេខបណ្តឹង/សំណុំរឿង និងសេចក្តីសម្រេច

- បណ្តឹង/សំណុំរឿងលេខ.................... ចុះថ្ងៃទី.......... ខែ............ ឆ្នាំ............ វេលាម៉ោង............
- សេចក្តីសម្រេចលេខ.................................ចុះថ្ងៃទី...............ខែ................ឆ្នាំ............

២. អត្តសញ្ញាណអ្នកប្តឹង

- ឈ្មោះអ្នកប្តឹង................................................ភេទ..............ថ្ងៃខែឆ្នាំកំណើត..............
- ទីលំនៅបច្ចុប្បន្នផ្ទះលេខ..............ផ្លូវ............ភូមិ..............ឃុំ សង្កាត់..................
  ក្រុង ស្រុក ខណ្ឌ.....................................................រាជធានី ខេត្ត.................
- តួនាទី/មុខងារ..........................................................................

៣. កម្មវត្ថុនៃបណ្តឹង..........................................................................

...................................................................................................

...................................................................................................

៤. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| រាជធានី ខេត្ត | | |
|---|---|---|
| លេខកូដ | | |

| ក្រុង ស្រុក ខណ្ឌ |
|---|
| |

| ឃុំ សង្កាត់ | | | |
|---|---|---|---|
| លេខកូដ | | | |

| លេខកូដការិយាល័យ | | | |
|---|---|---|---|
| | | | |

### សម្រេច

...................................................................................................

...................................................................................................

...................................................................................................

...................................................................................................

...................................................................................................

...................................................................................................

...................................................................................................

...................................................................................................

**បានស្រង់ត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ........................ខែ..............ឆ្នាំ....................ព.ស............

..................................ថ្ងៃទី..........ខែ............ឆ្នាំ............

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច**

**ហត្ថលេខា និងត្រា**

**លេខាធិការសវនាការ ឬអង្គប្រជុំសម្រេច**

**ហត្ថលេខា**

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញដោយក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច

## ឧបសម្ព័ន្ធទី ៣
## បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា
## ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង

ដើម្បីរក្សាសណ្ដាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការដូចជា៖
 - ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត
 - ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣. ហាមយកក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦. ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៧. ក្នុងករណីជនណាបង្កបញ្ហាអ្វីមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្ដេញជននោះ ចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បោះពុម្ព និងផ្សព្វផ្សាយដោយ
គ.ជ.ប

ឆ្នាំ ២០១៨

ទូរស័ព្ទ/ទូរសារ: ០២៣ ២១៤ ៣៧៤. ២១៤ ២៣១. ០១២ ៨៥៥ ០១៨
E_mail: necinfo@forum.org.kh, www.necelect.org.kh, www.voterlist.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
(គ.ជ.ប)

# សៀវភៅណែនាំ

## ស្តីពី

## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
## សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
## នីតិកាលទី៦

# ឧបសម្ព័ន្ធទី ៤
# នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូបបូជានៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថា បានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវរ័ត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថា ជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិតតាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយបងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនាអស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិតព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរមានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អានលុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿងសមដូចប្រាថ្នាកុំបីអាក់ខានឡើយ។

### ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ ទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។